**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**
លេខ ៖ ១៧២ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់តាំង ផ្ទាំងឃោសនា ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា

-------

### រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញសេចក្តីជូនដំណឹងលេខ ១៣៥ សជណ.សរ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០២ ស្តីពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១១ ខែមករា ឆ្នាំ២០០២ និងស្មារតីអង្គប្រជុំអន្តរក្រសួង នាទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០២

**សម្រេច**

ប្រការ ១.-

- ផ្ទាំងយីហោ គឺគ្រឿងបង្ហាញ និង សំគាល់នាមរបស់អាជីវករ គ្រឹះស្ថាននានា ដែលធ្វើការផលិត ធ្វើសេវាកម្ម ឬ ធ្វើពាណិជ្ជកម្ម។
- ផ្ទាំងផ្សាយពាណិជ្ជកម្ម គឺជាគ្រឿងបង្ហាញ និង ផ្សព្វផ្សាយ យីហោ ឬ មុខទំនិញ សំដៅទាក់ទាញអតិថិជន ក្នុងគោលដៅធ្វើអាជីវកម្ម។
- ផ្ទាំងសញ្ញា គឺជាគ្រឿងសំគាល់ និង បង្ហាញអំពីព្រឹត្តិការណ៍ ព័ត៌មាន សកម្មភាព និមិត្តរូប ពេលវេលា ឈ្មោះ ជូនសាធារណជន សំរាប់ចំណាំ ចងចាំ និង អនុវត្ត។

ប្រការ ២.-

អំពីរូបភាព ការដាក់តាំងផ្សព្វផ្សាយ និង ការគ្រប់គ្រងត្រួតពិនិត្យ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវសរសេរឱ្យបានត្រឹមត្រូវតាមពាក្យពេចន៍ និង អក្ខរាវិរុទ្ធជា អក្សរខ្មែរ ដោយអនុវត្តតាមវចនានុក្រមរបស់សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ជួន ណាត បោះពុម្ព នាឆ្នាំ១៩៦៧-១៩៦៨ ជាមូលដ្ឋាន។

អក្សរខ្មែរត្រូវសរសេរឲ្យបានធំជាងអក្សរបរទេស ហើយដាក់នៅជួរខាងលើគេបំផុត។

ប្រការ ៣.-

អក្សរបរទេសអាចសរសេរនៅពីខាងក្រោមហើយមានទំហំពាក់កណ្តាលនៃអក្សរខ្មែរ។ អក្សរបរទេសត្រូវសរសេរឲ្យបានត្រឹមត្រូវតាមពាក្យពេចន៍ អក្ខរាវិរុទ្ធជាអក្សរបរទេសនិមួយៗ ដើម្បីលើកតម្កើងកិត្យានុភាពជាតិ។

ប្រការ ៤.-

ម្ចាស់ដាក់តាំង និង ផ្សព្វផ្សាយ ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម ផ្ទាំងសញ្ញា ត្រូវកែលំអរឱ្យបានសមស្របតាមប្រកាសនេះ។

ប្រការ ៥.-

រាជធានីភ្នំពេញ ខេត្តសៀមរាប និង ក្រុងព្រះសីហនុ ត្រូវអនុវត្តជាបន្ទាន់នូវកិច្ចការនេះឱ្យបាន

ចប់ជាស្ថាពរ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០២។

**ប្រការ ៦.-**

ខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជាដែលពុំមានចែងក្នុងប្រការ ៥ ត្រូវអនុវត្តកិច្ចការនេះឱ្យបានចប់ជាស្ថាពរនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២។

**ប្រការ ៧.-**

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង ទទួលរូបភាព និង ខ្លឹមសារ ត្រូវសហការជាមួយអាជ្ញាធរដែនដី និង អង្គភាពជំនាញពាក់ព័ន្ធ ដើម្បីអនុវត្តតាមប្រកាសនេះឱ្យទទួលបានលទ្ធផលល្អ។

**ប្រការ ៨.-**

គ្រប់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជារៀងរាល់ខែអំពីលទ្ធផលនៃការអនុវត្តន៍តាមប្រកាសនេះផ្ញើមកក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល។

**ប្រការ ៩.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គ្រប់នាយកដ្ឋានក្រោមឳវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង គ្រប់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**នរោត្តម បុប្ផាទេវី**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ